ក្រុមប្រឹក្សាអាជ្ញាកណ្ដាល
THE ARBITRATION COUNCIL

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ និង ឈ្មោះសំណុំរឿង ៖ ០២៣/១៩ - យីនស៍ ថេកស្ដាយ (ខេមបូឌា) ឯ.ក
កាលបរិច្ឆេទនៃសេចក្ដីបង្គាប់ ៖ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩

# សេចក្ដីបង្គាប់អាជ្ញាកណ្ដាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្ដីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្ដាល

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ អ៊ុក រី
អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ អន ណន
ប្រធានក្រុមអាជ្ញាកណ្ដាលជ្រើសរើសឡើងដោយអាជ្ញាកណ្ដាលទាំងពីរខាងលើ ៖ គង់ ផល្លៈ

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន យីនស៍ ថេកស្ដាយ (ខេមបូឌា) ឯ.ក**
អាសយដ្ឋាន ៖ ភូមិព្រៃទា សង្កាត់កាកបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១២ ៦២៦ ៨៦៨ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការ៖

១- លោក ហំ ភា មេធាវី
២- លោក ជុំ ពេជ្រពន្លឺ ជំនួយការមេធាវី
៣- លោក ប៉ាន់ ពិសិដ្ឋ រដ្ឋបាល

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន យីនស៍ ថេកស្ដាយ (ខេមបូឌា) ឯ.ក**
អាសយដ្ឋាន ៖ ភូមិព្រៃទា សង្កាត់កាកបទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១០ ៤៧ ៣៨ ០១ ទូរសារ ៖ គ្មាន
តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

១- លោក តែប គុន ប្រធានសហព័ន្ធសហជីពអភិវឌ្ឍន៍កម្មករ
២- លោក សៅ សុជាតិ មន្ត្រីសហព័ន្ធសហជីពអភិវឌ្ឍន៍កម្មករ
៣- កញ្ញា ឡាយ សុចិត្រ ជំនួយការផ្នែកកាប់ចេញ

| | |
|---|---|
| ៤- លោក សុន ពៅ | ជាងម៉ាស៊ីន |
| ៥- លោកស្រី វ៉ែន សារ៉ុម | ជំនួយការចល័ត |
| ៦- កញ្ញា អ៊ឹម សុខណៃ | កម្មករផ្នែកដេរ |
| ៧- លោកស្រី ប៉ាន់ សុភា | ជំនួយការចល័ត |
| ៨- លោក សំ សុខរីម | ផ្នែកពិនិត្យគុណភាព |
| ៩- លោកស្រី អ៊ិត សុខែម | ផ្នែកតុកាត់ |
| ១០- លោកស្រី អ៊ឹម សារ៉ាន់ | ផ្នែកដេរ |
| ១១- លោក សុខ លីវ៉ារិន | ផ្នែកតុកាត់ |
| ១២- លោកស្រី ស្រី វង្ឃា | ផ្នែកដេរ |
| ១៣- លោកស្រី ឯម ឌី | ផ្នែកកាត់ព្រុយ |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

- ភាគីតំណាងកម្មករនិយោជិត នៅតែប្រកាន់ជំហរសុំឲក្រុមហ៊ុន យីនស៍ ថេកស្តាយ (ខេមបូឌា) ឯ.ក ធ្វើការទូទាត់ផ្តាច់អតីតភាពការងារ និងអត្ថប្រយោជន៍ផ្សេងៗ ចំនួន ៥ ចំណុច គឺ៖ ប្រាក់ទូទាត់ការជូនដំណឹងមុន, ប្រាក់បំណាច់អតីតភាពការងារ, ប្រាក់សោហ៊ុយជំងឺចិត្ត, ប្រាក់ទូទាត់ការឈប់សម្រាកប្រចាំឆ្នាំដែលមិនទាន់ប្រើអស់, ប្រាក់ឈ្នួលដែលមិនទាន់បានបើក ឬប្រាក់ឈ្នួលចុងក្រោយ ជាមួយក្រុមហ៊ុន ដុងប៊ូ សាំមីត (ខេមបូឌា)។ ដោយឡែក ភាគីក្រុមហ៊ុន យីនស៍ ថេកស្តាយ (ខេមបូឌា) ឯ.ក បានបញ្ជាក់ថា ក្រុមហ៊ុនព្រមទទួលខុសត្រូវទាំងស្រុង នូវអ្វីៗដែលកម្មករនិយោជិតត្រូវទទួលបានពីក្រុមហ៊ុន ដុងប៊ូ សាំមីត (ខេមបូឌា) ទៅតាមប្រកាស ៤៤៣ ស្តីពីការទូទាត់ប្រាក់អតីតភាពការងារ និងច្បាប់ស្តីពីការងារ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញា-កណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ២២០ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ (អាណត្តិទី១៦)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានព្រមសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន យីនស៍ ថេកស្តាយ (ខេមបូឌា) ឯ.ក លេខ ១៩២ ក.ប/អក/វក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៩។

THE ARBITRATION COUNCIL

## សវនាការ និង សន្ទេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃពុធ ៨កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ឃីនស៍ ថេកស្តាយ (ខេមបូឌា) ឯ.ក ស្តីពីការស្នើសុំជួយដោះស្រាយនូវលក្ខខណ្ឌការងារ ចំនួន ១ចំណុច។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញ ធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សា នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ចំណុចមិនសះជា ចំនួន ១ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១ ខែមីនា ឆ្នាំ២០១៩ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ឃីនស៍ ថេកស្តាយ (ខេមបូឌា) ឯ.ក លេខ ១៩២ក.ប/អក/វក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៩។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជា ចំនួន ១ ចំណុច នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។ ភាគីទាំងពីរ មានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ១ចំណុចនេះ និងបានធ្វើការផ្សះផ្សាលើចំណុចវិវាទបន្ថែមទៀត ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នានោះទេ។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ និងថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ។

កាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាលគឺ នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន ៖**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់ក្រុមហ៊ុន យីនស៍ ថេកស្តាយ (ខេមបូឌា) ឯ.ក ប្រគល់សិទ្ធិជូនលោកមេធាវី ហំ ភា ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩។

២- ប័ណ្ណពន្ធប៉ាតង់ ក្រុមហ៊ុន យីនស៍ ថេកស្តាយ (ខេមបូឌា) ឯ.ក លេខ PTL ២០១៨១២១៥៥៤ អពជ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៨។

៣-វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម របស់ក្រុមហ៊ុន យីនស៍ ថេកស្តាយ (ខេមបូឌា) ឯ.ក លេខ MOC-៥៨៩១៩៣៩៤ ពណ.ចបព ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨។

៤- បញ្ជីឈ្មោះបុគ្គលិក។

៥- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន យីនស៍ ថេកស្តាយ (ខេមបូឌា) ឯ.ក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩។

៦- កំណត់ហេតុស្តីពីការសាកសួរព័ត៌មានតំណាងនិយោជក នៃក្រុមហ៊ុន យីនស៍ ថេកស្តាយ (ខេមបូឌា) ឯ.ក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩។

៧- កំណត់ហេតុស្តីពីការស្វែងរកដំណោះស្រាយ និងសម្របសម្រួលករណីក្រុមហ៊ុន ដុងប៊ូ សាំមីត (ខេមបូឌា) ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៩។

៨- លក្ខន្តិកៈក្រុមហ៊ុន យីនស៍ ថេកស្តាយ (ខេមបូឌា) ឯ.ក បានតំកល់ទុកលេខ ០០០៣៨១៥៧ ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៨ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម។

៩- កិច្ចព្រមព្រៀងផ្ទេរកម្មករ ពីក្រុមហ៊ុន ដុងប៊ូ សាំមីត (ខេមបូឌា) ឯ.ក ទៅក្រុមហ៊ុន យីនស៍ ថេកស្តាយ (ខេមបូឌា) ឯ.ក ធ្វើនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩។

១០- សារណាលេខ ០៣២ គ្លី/១៩ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ របស់មេធាវី ហំ ភា គោរពជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសារណានៃសំណុំរឿងវិវាទការងាររួម លេខ ០២៣/១៩ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតរបស់តំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន យីនស៍ ថេកស្តាយ (ខេមបូឌា) ឯ.ក គោរពជូន ប្រធានសហព័ន្ធសហជីពអភិវឌ្ឍន៍កម្មករ ស្តីពីស្នើសុំជួយអម និងប្រឹក្សាយោបល់ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន យីនស៍ ថេកស្តាយ (ខេមបូឌា) ឯ.ក លេខ ១៩២ ក.ប/អក/វក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន យីនស៍ ថេកស្តាយ (ខេមបូឌា) ឯ.ក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩៕

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន យីនស៍ ថេកស្តាយ (ខេមបូឌា) ឯ.ក លេខ ០០៥/១៩ កប/អក/កបវ២ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ របស់នាយកដ្ឋានវិវាទការងារ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ១៥២ កប/អក/វក/លកអ. ចុះថ្ងៃពុធ ១កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៩។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ១៥៣ កប/អក/វក/លកអ. ចុះថ្ងៃពុធ ១កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៩។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន យីនស៍ ថេកស្តាយ (ខេមបូឌា) ឯ.ក គឺជាក្រុមហ៊ុនដែលមានសកម្មភាពចម្បងក្នុងការកាត់ដេរសម្លៀកបំពាក់ និងបានទទួលវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្ម ក្រោមលេខ ០០០៣៨១៥៧ ចុះថ្ងៃទី ៥ ខែធ្នូ ឆ្នាំ២០១៨។
- នាយកដ្ឋានវិវាទការងារ បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិត ចំនួន ៦នាក់ ដូចជា ៖ ឡាយ សុចិត្រ, អ៊ឹម សាវ៉ាន់, រ៉ែន សារ៉ុម, អ៊ឹម សុខណៃ, ស្រី វង្ឋា និង បាន់ សុភា ជាអ្នកតំណាងភាគីកម្មករនិយោជិតនៃក្រុមហ៊ុន យីនស៍ ថេកស្តាយ (ខេមបូឌា) ឯ.ក ក្នុងការដោះស្រាយវិវាទការងាររួម តាមរយៈលិខិតលេខ ០០៥/១៩ កប/អក/កបវ២ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩។ កម្មករនិយោជិតដែលជាអ្នកតំណាងភាគីកម្មករនិយោជិត ចំនួន ៦នាក់ ដែលមានឈ្មោះនៅក្នុងលិខិតបញ្ជាក់អ្នកតំណាងខាងលើ មានវត្តមាននៅថ្ងៃសវនាការក្រុមប្រឹក្សាអាជ្ញាកណ្តាល។
- មិនមានអង្គហេតុណាមួយបញ្ជាក់ថា នៅក្នុងក្រុមហ៊ុននេះ មានសហជីពដែលមានភាពជាតំណាងបំផុតទេ។

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារឲនិយោជកក្រុមហ៊ុន យីនស៍ ថេកស្តាយ (ខេមបូឌា) ឯ.ក ធ្វើការទូទាត់ផ្តាច់អតីតភាពការងារ និងអត្ថប្រយោជន៍ផ្សេងៗ ចំនួន ៥ ចំណុច គឺ៖ ប្រាក់ទូទាត់ការជូនដំណឹងមុន, ប្រាក់បំណាច់អតីតភាពការងារ, ប្រាក់សោហ៊ុយជំងឺចិត្ត, ប្រាក់ទូទាត់ការឈប់សម្រាកប្រចាំឆ្នាំដែលមិនទាន់ប្រើអស់, ប្រាក់ឈ្នួលដែលមិនទាន់បានបើក ឬប្រាក់ឈ្នួលចុងក្រោយជាមួយក្រុមហ៊ុន ដុងប៊ូ សាំមីត (ខេមបូឌា)**

- ភាគីទាំងពីរបានទទួលស្គាល់ថា ៖ កម្មករនិយោជិតទាំងអស់ គឺជាកម្មករនិយោជិតដែលបានបំពេញការងារ ឲក្រុមហ៊ុន ដុងប៊ូ សាំមីត មុនពេលមានការផ្ទេរវិវាទកើតឡើង។ ក្រុមហ៊ុន ដុងប៊ូ សាំមីត បានបើកដំណើរការផលិតកម្ម ចំនួន ៨ឆ្នាំ ហើយ និងប្រើប្រាស់កិច្ចសន្យាការងារមានថិរវេលាមិនកំណត់

- ក្រុមហ៊ុន ដុងប៊ូ សាំមីត បានផ្ទេរកម្មករនិយោជិតទាំងអស់របស់ខ្លួន ទៅឲក្រុមហ៊ុន យីនស៍ ថេកស្តាយ (ខេមបូឌា) ឯ.ក តាមរយៈកិច្ចព្រមព្រៀង ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩។
- តាមរយៈកិច្ចព្រមព្រៀង ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ និយោជកថ្មីនេះ (ក្រុមហ៊ុន យីនស៍ ថេកស្តាយ) បានរក្សាប្រាក់ឈ្នួល អត្ថប្រយោជន៍ផ្សេងៗ តួនាទី និងអតីតភាពការងាររបស់កម្មករនិយោជិត នៃក្រុមហ៊ុន ដុងប៊ូ សាំមីត ឲនៅដដែលទាំងអស់ ដោយមិនមានការផ្លាស់ប្តូរអ្វីនោះទេ។
- កម្មករនិយោជិត នៃក្រុមហ៊ុន ដុងប៊ូ សាំមីត ដែលបានចូលធ្វើការនៅក្រុមហ៊ុន យីនស៍ ថេកស្តាយ បានទាមទារឲនិយោជកទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារ ចំនួន ៥ ចំណុច ជូនកម្មករនិយោជិតជាមួយក្រុមហ៊ុន ដុងប៊ូ សាំមីត ទោះបីជាពួកគេបាន និងកំពុងធ្វើការនៅក្រុមហ៊ុន យីនស៍ ថេកស្តាយ ហើយ ក៏ដោយ តាមរយៈការធ្វើកូដកម្ម នៅថ្ងៃទី២៧-២៨ ខែកុម្ភៈ ឆ្នាំ២០១៩។
- និយោជកថ្មីនេះ (ក្រុមហ៊ុន យីនស៍ ថេកស្តាយ) មិនយល់ព្រមតាមការទាមទារនេះទេ ដោយមូលហេតុថា៖
    - យោងតាមមាត្រា ៨៧ នៃច្បាប់ស្តីពីការងារ ពាក់ព័ន្ធនឹងការកែប្រែស្ថានភាពគតិយុត្ត ពីនិយោជកចាស់មកនិយោជកថ្មី នោះនិយោជកថ្មី ត្រូវរក្សាកិច្ចសន្យាការងារ និងអត្ថប្រយោជន៍ផ្សេងៗ របស់កម្មករនិយោជិតឲនៅដដែល។ ករណីនេះ គឺនិយោជកថ្មី (ក្រុមហ៊ុន យីនស៍ ថេកស្តាយ) បានរក្សាកិច្ចសន្យាការងារ, អតីតភាពការងារ និងអត្ថប្រយោជន៍ផ្សេងៗ ជូនកម្មករនិយោជិតទាំងអស់។ ហេតុនេះ និយោជកមិនអាចទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារជូនកម្មករនិយោជិតនោះទេ។ ជាងនេះទៀត គិតចាប់ពីពេលផ្ទេរក្រុមហ៊ុន និងកម្មករនិយោជិតនេះមក គឺនិយោជកមិនបានផ្តាច់កិច្ចសន្យាការងារ ឬបញ្ឈប់កម្មករនិយោជិតណាម្នាក់ពីការងារនោះដែរ។
    - និយោជកមានកិច្ចព្រមព្រៀងផ្ទេរកម្មករពីក្រុមហ៊ុន ដុងប៊ូ សាំមីត (ខេមបូឌា) ឯ.ក ទៅក្រុមហ៊ុន យីនស៍ ថេកស្តាយ (ខេមបូឌា) ឯ.ក នៅក្នុងកិច្ចព្រមព្រៀងនោះបានកំណត់ថា ៖ ក្រុមហ៊ុន ដុងប៊ូ សាំមីត បានសម្រេចយល់ព្រមផ្ទេរកម្មករកម្មការនីទាំងអស់ ដែលស្ថិតនៅក្នុងការគ្រប់គ្រងរបស់ក្រុមហ៊ុន ដុងប៊ូ សាំមីត ទៅបំពេញការងារនៅក្នុងក្រុមហ៊ុន យីនស៍ ថេកស្តាយ ទៅតាមការស្ម័គ្រចិត្តរបស់កម្មករនិយោជិត និងនិយោជក។ ក្រុមហ៊ុន យីនស៍ នឹងទទួលស្គាល់អតីតភាពការងាររបស់កម្មករនិយោជិតទាំងអស់។ ចំពោះកម្មករនិយោជិតដែលមិនព្រមផ្លាស់ប្តូរមកបំពេញការងារ នៅក្នុងក្រុមហ៊ុន យីនស៍ ថេកស្តាយ នោះទេ ក្រុមហ៊ុន យីនស៍ ថេកស្តាយ នឹងមិនទទួលខុសត្រូវចំពោះប្រាក់អតីតភាព និងប្រាក់អត្ថ-ប្រយោជន៍ផ្សេងៗឡើយ។
    - ចំពោះការប្តូរកិច្ចសន្យាការងាររបស់កម្មករនិយោជិត ពីក្រុមហ៊ុន ដុងប៊ូ សាំមីត មកចុះជាមួយក្រុមហ៊ុន យីនស៍ ថេកស្តាយ គឺនិយោជកបានរក្សាថ្ងៃខែចូលធ្វើការរបស់គាត់នៅដដែល ដោយដាក់ថ្ងៃខែចូលធ្វើការដំបូងរបស់កម្មករនិយោជិតម្នាក់ៗ។
- ភាគីកម្មករនិយោជិតបានបញ្ជាក់ពីមូលហេតុនៃការទាមទារថា ៖
    - កាលពីមុន កម្មករនិយោជិតទាំងអស់នេះ គឺជាកម្មករនិយោជិតនៃក្រុមហ៊ុន ដុងប៊ូ សាំមីត ហើយបច្ចុប្បន្ននេះ កិច្ចសន្យាការងាររបស់កម្មករនិយោជិត ជាមួយក្រុមហ៊ុន ដុងប៊ូ សាំមីត

គឺត្រូវបានរំលាយហើយ ដោយមូលហេតុថា កម្មករនិយោជិតលែងជាកម្មករនិយោជិតនៃក្រុមហ៊ុន ដុងប៊ូ សាំមីត ព្រោះបច្ចុប្បន្ន ពួកគាត់ជាកម្មករនិយោជិតនៃក្រុមហ៊ុន យីនស៍ ថេកស្ថាយ វិញ ដោយសារមានការផ្លាស់ប្ដូរនិយោជកថ្មី (ក្រុមហ៊ុនថ្មី)។ ម្យ៉ាងទៀត ក្រុមហ៊ុន យីនស៍ ថេកស្ថាយ បានទទួលកម្មករនិយោជិតប្ដូរកិច្ចសន្យាការងារពីក្រុមហ៊ុន ដុងប៊ូ សាំមីត មកចុះកិច្ចសន្យាការងារជាមួយក្រុមហ៊ុន យីនស៍ ថេកស្ថាយ វិញដែរ។

- យោងតាមមាត្រា ១១៦ នៃច្បាប់ស្តីពីការងារបានចែងថា ក្នុងករណីរំលាយកិច្ចសន្យាការងារ ប្រាក់ឈ្នួល និងប្រាក់បំណាច់គ្រប់ប្រភេទត្រូវបើកក្នុងរយៈពេលសែសិបប្រាំបីម៉ោង បន្ទាប់ពីថ្ងៃឈប់ធ្វើការ។
- ភាគីកម្មករនិយោជិតបញ្ជាក់ថា នៅពេលដែលមានការផ្លាស់ប្ដូរក្រុមហ៊ុន គឺនិយោជក (ក្រុមហ៊ុន ដុងប៊ូ សាំមីត) មិនបានប្រជុំពិភាក្សាជាមួយកម្មករនិយោជិតនោះទេ ទើបតែនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៩ ទើបនិយោជកបានប្រកាសប្រាប់កម្មករនិយោជិតថា កម្មករនិយោជិតទាំងអស់នេះ ត្រូវប្ដូរពីកម្មករនិយោជិតនៃក្រុមហ៊ុន ដុងប៊ូ សាំមីត ទៅជាកម្មករនិយោជិតនៃក្រុមហ៊ុន យីនស៍ ថេកស្ថាយ វិញ។

- និយោជកថ្មីនេះ (ក្រុមហ៊ុន យីនស៍ ថេកស្ថាយ) បញ្ជាក់ថា កម្មករនិយោជិតទាំងអស់ នៅតែបន្តធ្វើការនៅធម្មតាទាំងអស់ ដោយមិនមានកម្មករនិយោជិតណាម្នាក់ត្រូវបាននិយោជកបញ្ឈប់ពីការងារ ឬផ្ដាច់កិច្ចសន្យាការងារឡើយ។

## ហេតុផលនៃសេចក្តីសម្រេច ៖

មុននឹងពិចារណាចំណុចទាមទារនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការពិចារណាអំពីភាគីដើមបណ្ដឹងជាមុនសិន ដូចខាងក្រោម ៖

កថាខណ្ឌទី១ នៃមាត្រា ៥៤ នៃច្បាប់ស្ដីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ចែងថា ៖ *"ភាពជាតំណាងបំផុតនៃសហជីព ត្រូវបានទទួលស្គាល់នៅក្នុងក្របខ័ណ្ឌនៃសហគ្រាស ឬគ្រឹះស្ថាន។ សម្រាប់គោលបំណងនៃការចរចាអនុសញ្ញារួម ឬដោះស្រាយវិវាទការងាររួម គឺសហជីពដែលមានភាពជាតំណាងបំផុតទទួលបានសិទ្ធិផ្ដាច់មុខ។"*។

យោងតាមខ្លឹមសារនៃកថាខណ្ឌទី១ នៃមាត្រា ៥៤ នៃច្បាប់ស្ដីពីសហជីពខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ថា មានតែសហជីពដែលមានភាពជាតំណាងបំផុតប៉ុណ្ណោះ ដែលមានសិទ្ធិផ្ដាច់មុខនៅក្នុងការចរចាបង្កើតអនុសញ្ញារួម និងដោះស្រាយវិវាទការងាររួមនៅក្នុងសហគ្រាស ឬគ្រឹះស្ថានរបស់ខ្លួន។ សិទ្ធិផ្ដាច់មុខក្នុងការដោះស្រាយវិវាទការងាររួមនេះ សំដៅលើសិទ្ធិក្នុងការនាំយកវិវាទ និងធ្វើជាតំណាងឲ្យកម្មករនិយោជិតនៅគ្រប់នីតិវិធីដោះស្រាយវិវាទការងាររួម ដោយរួមបញ្ចូលទាំងនីតិវិធីដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលផងដែរ។ *(សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្ដាល លេខ ១៨០/១៦-ស៊ីម៉ង់ត៍ កម្ពុជាចក្រីទីង និងលេខ ១៧១/១៦-ដេវើលីន ខូអិលធីឌី )*

យោងតាមអង្គហេតុបញ្ជាក់ថា នៅក្នុងក្រុមហ៊ុននេះមិនទាន់មានសហជីពដែលមានភាពជាតំណាងបំផុតនោះទេ។

ប្រការ ១៦ នៃប្រកាសលេខ ៣០៣ ក.ប/ប្រ.ក.គ.ប.ក ស្តីពីភាពជាតំណាងបំផុតនៃសហជីព និងបែបបទ និងនីតិវិធីដើម្បីទទួលបានភាពជាតំណាងបំផុត ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨ ចែងថា ៖

*"ក្នុងករណីសហគ្រាស គ្រឹះស្ថានដែលពុំទាន់មានសហជីព ឬពុំទាន់មានសហជីពដែលមានភាពជាតំណាងបំផុត ការដោះស្រាយវិវាទការងាររួម ត្រូវដោះស្រាយដោយអ្នកតំណាងកម្មករនិយោជិត។"*។

លើសពីនេះ ប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ស្តីពីការផ្ទេរប្រតិភូកម្មមុខងារ ក្នុងការធ្វើបណ្តឹងអំពីវិវាទការងាររួម និងចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចរចា ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចែងថា ៖ *"ត្រូវបានផ្ទេរប្រតិភូកម្មជូនដល់ប្រធាននាយកដ្ឋានវិវាទការងារ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត នូវមុខងារ ដូចខាងក្រោម ៖*

...

*- ចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចរចា សម្រាប់ដោះស្រាយវិវាទការងាររួម។"*។

យោងតាមប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ថា នាយកដ្ឋានវិវាទការងារ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត មានមុខងារក្នុងការទទួលស្គាល់កម្មករនិយោជិត ឲធ្វើជាតំណាងរបស់ភាគីកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទការងាររួម។ ដូច្នេះ កម្មករនិយោជិតដែលត្រូវបានទទួលស្គាល់ដោយនាយកដ្ឋានវិវាទការងារ ឬប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត មានសិទ្ធិស្របច្បាប់ក្នុងការតំណាងឲភាគីកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទការងាររួម ដោយរួមទាំងនៅដំណាក់កាលដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ នៅពេលមិនទាន់មានវត្តមានរបស់សហជីពមានភាពតំណាងបំផុត។ (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ២២៣/១៦-យូនីកតា ហ្គេកណាឡូជី (ខេមបូឌា), លេខ ២២៤/១៦-កាស៊ីណូកោះមាស និង សណ្ឋាគារ, លេខ ០០៨/១៧-ថបរ៉ែលជ៍ ហ្គាមិន (ខេមបូឌា) អិលធីឌី និងលេខ ២៣៧/១៦-ហ្សិណា-ដាយដុង (ខេមបូឌា) អេឡិចត្រូនិច*)។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របទៅនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

ក្នុងសំណុំរឿងនេះ នាយកដ្ឋានវិវាទការងារ បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម លេខ ០០៥/១៩ កប/អក/កបវ២ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩ ដែលមានកម្មករនិយោជិត ចំនួន ៦នាក់ ដូចជា ៖ ឡាយ សុចិត្រ, អ៊ឹម សាក៉ន់, រ៉ន សារ៉ុម, អ៊ឹម សុខណៃ, ស្រី វដ្ឋា និង បាន់ សុភា ជាអ្នកតំណាងភាគីកម្មករនិយោជិតនៃក្រុមហ៊ុន យីនស៍ ថេកស្តាយ (ខេមបូឌា) ឯ.ក ក្នុងការដោះស្រាយវិវាទការងាររួម។ នៅថ្ងៃសវនាការក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺមានវត្តមានរបស់កម្មករនិយោជិតដែលជាអ្នកតំណាងភាគីកម្មករនិយោជិតទាំង ៦នាក់ ដែលមានឈ្មោះនៅក្នុងលិខិតបញ្ជាក់អ្នកតំណាងខាងលើ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតចំនួន ៦នាក់ ខាងលើ គឺមានសិទ្ធិធ្វើជាតំណាងកម្មករនិយោជិត នៃក្រុមហ៊ុន យីនស៍ ថេកស្តាយ (ខេមបូឌា) ឯ.ក ក្នុងការដោះស្រាយវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្របតាមប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ខាងលើ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាចំណុចវិវាទនៅក្នុងសំណុំរឿងនេះ សម្រាប់កម្មករនិយោជិត នៅក្នុងក្រុមហ៊ុន យីនស៍ ថេកស្តាយ (ខេមបូឌា) ឯ.ក ដែលជាដើមបណ្តឹង។

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារឲនិយោជកក្រុមហ៊ុន យីនស៍ ថេកស្ទាយ (ខេមបូឌា) ឯ.ក ធ្វើការទូទាត់ផ្តាច់អតីតភាពការងារ និងអត្ថប្រយោជន៍ផ្សេងៗចំនួន ៥ចំណុច គឺ៖ ប្រាក់ទូទាត់ការជូនដំណឹងមុន, ប្រាក់បំណាច់អតីតភាពការងារ, ប្រាក់សោហ៊ុយជំងឺចិត្ត, ប្រាក់ទូទាត់ការឈប់សម្រាកប្រចាំឆ្នាំដែលមិនទាន់ប្រើអស់, ប្រាក់ឈ្នួលដែលមិនទាន់បានបើក ឬប្រាក់ឈ្នួលចុងក្រោយ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើនិយោជកក្រុមហ៊ុន យីនស៍ ថេកស្ទាយ (ខេមបូឌា) ឯ.ក មានកាតព្វកិច្ចទូទាត់ផ្តាច់អតីតភាពការងារ និងអត្ថប្រយោជន៍ផ្សេងៗចំនួន ៥ចំណុច ដូចជា ៖ ប្រាក់ទូទាត់ជួសការជូនដំណឹងមុន, ប្រាក់បំណាច់អតីតភាពការងារ, ប្រាក់សោហ៊ុយជំងឺចិត្ត, ប្រាក់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលមិនទាន់ប្រើអស់, ប្រាក់ឈ្នួលដែលមិនទាន់បានបើក ឬប្រាក់ឈ្នួលចុងក្រោយ (ខេមបូឌា) ជូនកម្មករនិយោជិត ដែរ ឬទេ?

មាត្រា ៦៦៧ ស្តីពីភាពផ្តាច់មុខលើបុគ្គល នៃកិច្ចសន្យាការងារ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានចែងថា ៖

*"១. បើគ្មានការយល់ព្រមពីកម្មករនិយោជិតទេ និយោជកពុំអាចធ្វើអនុប្បទានសិទ្ធិនោះឲទៅតតិយជនបានឡើយ។*

*២. បើគ្មានការយល់ព្រមពីនិយោជកទេ កម្មករនិយោជិត ពុំអាចឲតតិយជនធ្វើពលកម្មជំនួសខ្លួនបានឡើយ។*

*៣. ប្រសិនបើភាគីណាមួយនៃកិច្ចសន្យាការងារ បានធ្វើផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី១ និងទី២ ខាងលើនេះ ភាគីម្ខាងទៀតអាចរំលាយកិច្ចសន្យានោះបាន។"*

យោងតាមមាត្រា ៦៦៧ នៃក្រមរដ្ឋប្បវេណី ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកអាចផ្ទេរ ឬធ្វើអនុប្បទានសិទ្ធិជានិយោជកលើកម្មករនិយោជិត ទៅឲជនដទៃទៀត(តតិយជន) បាន លុះណាតែមានការយល់ព្រមពីកម្មករនិយោជិត។ ប្រសិនបើការផ្ទេរ ឬធ្វើអនុប្បទានសិទ្ធិលើកិច្ចសន្យាការងាររបស់កម្មករនិយោជិត ដោយពុំមានការព្រមព្រៀងពីកម្មករនិយោជិត នោះភាគីកម្មករនិយោជិតអាចរំលាយកិច្ចសន្យាការងារនោះបាន។

លើសពីនេះ កថាខណ្ឌទី១ នៃមាត្រា ៨៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្ម មាត្រា ៨៧ ចំណងជើងចំណុច "គ" ផ្នែកទី៣ នៃជំពូកទី៤ មាត្រា ៨៩ មាត្រា ៩០ មាត្រា ៩១ មាត្រា ៩៤ មាត្រា ១១០ មាត្រា ១២០ និងមាត្រា ១២២ នៃច្បាប់ស្តីពីការងារដែលត្រូវប្រកាសឲប្រើដោយព្រះរាជក្រមលេខ ចស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលចូលជាធរមាន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨ (ចាប់ពីពេលនេះទៅហៅមាត្រា ៨៧ថ្មី នៃច្បាប់ស្តីពីការងារ) ចែងថា ៖ *"កាលបើកែប្រែស្ថានភាពគតិយុត្តិនៃនិយោជក មានជាអាទិ៍ដោយឧត្តរាធិការ "ការបន្តមរតក" ការលក់ ការបញ្ចូលមូលនិធិ ឬការផ្លាស់ប្តូរមូលនិធិ ការដាក់ជាក្រុមហ៊ុន នោះកិច្ចសន្យាការងារទាំងឡាយ ដែលកំពុងប្រតិបត្តិមកដល់ថ្ងៃមានកែប្រែនោះ ត្រូវស្ថិតនៅដដែល រវាងនិយោជកថ្មី និងកម្មករនិយោជិតក្នុងសហគ្រាសចាស់។..."*

យោងតាមមាត្រា ៨៧ថ្មី នៃច្បាប់ស្តីពីការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា នៅពេលមានការកែប្រែស្ថានភាពគតិយុត្តិរបស់និយោជក មានដូចជា ការបន្តមរតក ឬការលក់ ការបញ្ចូលមូលនិធិ ជាដើម និយោជកថ្មីត្រូវរក្សា និងអនុវត្តកិច្ចសន្យាការងារទាំងឡាយដែលកំពុងប្រតិបត្តិ មកដល់ថ្ងៃមានការកែប្រែនោះ ឲនៅដដែលរវាងនិយោជកថ្មី និងកម្មករនិយោជិតក្នុងសហគ្រាសចាស់។

យោងតាមការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ០៤៥/៨-ខ្វាន់ទុម ខ្លូស៊ីង (ខេមបូឌា) លីមីធីត បានបកស្រាយថា៖ការផ្លាស់ប្តូរស្ថានភាពគតិយុត្តិនៃនិយោជកចាស់ មកនិយោជកថ្មី ដែលមិនមានការប៉ះពាល់ដល់កិច្ចសន្យាការងារ និងអត្ថប្រយោជន៍ផ្សេងៗរបស់កម្មករនិយោជិតដែលធ្លាប់ទទួលបាននោះ និយោជកថ្មី មិនមានកាតព្វកិច្ចក្នុងការទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារជូនកម្មករនិយោជិតនោះទេ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញា-កណ្តាល នៅក្នុងសំណុំរឿងខាងលើនេះដែរ។

យោងតាមអង្គហេតុ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ក្រុមហ៊ុន ដុងប៊ូ សាំមីត បានផ្ទេរកម្មករនិយោជិតរបស់ខ្លួន ទៅឲក្រុមហ៊ុន យីនស៍ ថេកស្តាយ ហើយក្រុមហ៊ុន យីនស៍ ថេកស្តាយ បន្តប្រតិបត្តការក្រុមហ៊ុន ដោយប្រើប្រាស់កម្មករនិយោជិតនៃក្រុមហ៊ុន ដុងប៊ូ សាំមីត និងបានរក្សាប្រាក់ឈ្នួល អត្ថប្រយោជន៍ផ្សេងៗ តួនាទី និងអតីតភាពការងាររបស់កម្មករនិយោជិតឲនៅដដែលទាំងអស់ ដោយមិនមានការផ្លាស់ប្តូរអ្វីនោះទេ។ លើសពីនេះ គិតចាប់ពីពេលដែលមានការផ្លាស់ប្តូរនិយោជកថ្មី រហូតដល់បច្ចុប្បន្ននេះ កម្មករនិយោជិត នៅតែបន្តធ្វើការងារជាធម្មតា ដោយមិនមានការផ្លាស់ប្តូរអ្វីនោះទេ ហើយក៏មិនមានកម្មករនិយោជិតណាម្នាក់ត្រូវបាននិយោជកបញ្ឈប់ពីការងារនោះដែរ។ ហេតុនេះ យោងតាមមាត្រា ៦៦៧ នៃក្រមរដ្ឋប្បវេណី និងមាត្រា ៨៧ថ្មី នៃច្បាប់ស្តីពីការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតបានព្រមព្រៀងគ្នា ធ្វើការជាមួយនិយោជកថ្មីរួចហើយ ហើយនិយោជកថ្មីក៏បានរក្សាកិច្ចសន្យាការងារ, អត្ថប្រ-យោជន៍ និងអតីតភាពការងាររបស់កម្មករនិយោជិតនៅដដែលទាំងអស់។ ដូចនេះ និយោជកនៃក្រុមហ៊ុន យីនស៍ ថេកស្តាយ មិនមានកាតព្វកិច្ចក្នុងការទូទាត់ប្រាក់បំណាច់ផ្តាច់កិច្ចសន្យាការងារជូនកម្មករនិយោជិតនោះទេ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់កម្មករនិយោជិត ឲនិយោជកទូទាត់ផ្តាច់អតីតភាពការងារ និងអត្ថប្រយោជន៍ផ្សេងៗ ចំនួន ៥ចំណុច ដូចជា ៖ ប្រាក់ទូទាត់ជួសការជូនដំណឹងមុន, ប្រាក់បំណាច់អតីតភាពការងារ, ប្រាក់សោហ៊ុយជំងឺចិត្ត, ប្រាក់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលមិនទាន់ប្រើអស់, ប្រាក់ឈ្នួលដែលមិនទាន់បានបើក ឬប្រាក់ឈ្នួលចុងក្រោយ ជូនកម្មករនិយោជិត។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សា-អាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទ ៖**

- បដិសេធការទាមទាររបស់កម្មករនិយោជិតឲនិយោជកទូទាត់ផ្តាច់អតីតភាពការងារ និងអត្ថប្រយោជន៍ផ្សេងៗចំនួន ៥ ចំណុច ដូចជា ៖ ប្រាក់ទូទាត់ជួសការជូនដំណឹងមុន, ប្រាក់បំណាច់អតីតភាពការងារ, ប្រាក់សោហ៊ុយជំងឺចិត្ត, ប្រាក់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលមិនទាន់ប្រើអស់, ប្រាក់ឈ្នួលដែលមិនទាន់បានបើក ឬប្រាក់ឈ្នួលចុងក្រោយ ជូនកម្មករនិយោជិត។

ប្រភេទនៃសេចក្ដីបង្គាប់ ៖ សេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច

*សេចក្ដីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីបង្គាប់ ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល ក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ុក រី**

ហត្ថលេខា ៖ ----------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖ ----------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល ៖

ឈ្មោះ ៖ **គង់ ផល្លៈ**

ហត្ថលេខា ៖ ----------------------------

THE ARBITRATION COUNCIL